**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៩៩.០៧៤.៩២៤.ស.ជ.ណ

ថ្ងៃចន្ទ ១០កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសបុគ្គលិក

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណជន ឱ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជា នឹងធ្វើការជ្រើសរើសបុគ្គលិកទាំងពីរភេទ ដើម្បីចូលបម្រើការងារនៅអគ្គនាយកដ្ឋានគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ នៃធនាគារជាតិនៃកម្ពុជា ក្នុង **ក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា "ក"** ចំនួន **១០រូប**។ បេក្ខជនដែលបានជាប់ជាស្ថាពរក្នុងការជ្រើសរើសនេះ នឹងបំពេញតួនាទីជាសេដ្ឋវិទូ និងត្រូវចូលរួមចំណែកក្នុងការសិក្សាស្រាវជ្រាវ វិភាគស្ថានភាពសេដ្ឋកិច្ច និងរៀបចំគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុ។

បេក្ខជនទាំងពីរភេទត្រូវមានលក្ខណៈសម្បត្តិ និងបំពេញលក្ខខណ្ឌនៃការជ្រើសរើសដូចខាងក្រោម៖

១/. មានសញ្ជាតិខ្មែរ
២/. មានសញ្ញាបត្រអនុបណ្ឌិត និងបណ្ឌិត ផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬធនាគារ
៣/. មានចំណេះដឹងភាសាអង់គ្លេស ( IELTS ៦.០)
៤/. មានបទពិសោធន៍ក្នុងការស្រាវជ្រាវ និងវិភាគស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៥/. មានសុខភាពល្អ។

បេក្ខជនអាចមកទំនាក់ទំនងសាកសួរព័ត៌មានលម្អិតបន្ថែមទៀត នៅនាយកដ្ឋានបុគ្គលិកនៃធនាគារជាតិនៃកម្ពុជា ដែលមានទីតាំងនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ចន្លោះពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ១៥:០០ រសៀល រៀងរាល់ថ្ងៃធ្វើការ ឬតាមរយៈលេខទូរសព្ទ ០២៣ ៧២២ ២២១ / ០៨១ ៨៧៧ ២២៧។

- កាលបរិច្ឆេទទទួលពាក្យប្រឡង ៖ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ
- កាលបរិច្ឆេទឈប់ទទួលពាក្យប្រឡង ៖ **ថ្ងៃសុក្រ ទី៣០ ខែសីហា ឆ្នាំ២០២៤ វេលាម៉ោង ១១:០០នាទី**
- កាលបរិច្ឆេទប្រឡងនិងការធ្វើសម្ភាសន៍ ៖ ជូនដំណឹងពេលក្រោយ ។

**ត.ប.ទេសាភិបាល**
**អគ្គលេខាធិការ**

**គ្រួយ វាសនា**